# ផលិតកម្មដំណាំខ្នុរសំរាប់កសិករ



រៀបចំដោយមានការចូលរួមពីអង្គការ សន្តិសេនា សមាគមមនុស្សចាស់

ពោធិ៍ធំ អង្គការចិត្តធម៌ និង អង្គការ ស៊ី អារ អែស កម្មវិធីកសិកម្ម

ដក់ស្រង់ពីឯកសារឈើហូបផ្លែរបស់អង្គការ ប៉ាឌិក ស៊ីដសេ និង សាលាជាតិកសិកម្មព្រែកលៀប

# មាតិការ

ទំព័រ


១- សេចក្តីផ្តើម..........01

២- ការជ្រើសរើសពូជ..........01

៣- ការបណ្តុះកូន..........0២

ក. ជ្រើសរើសទីតាំងថ្នាល..........0២

ខ. ការរៀបចំថ្នាល..........0២

គ. ការបណ្តុះកូនខ្នុរ..........0៣

ឃ. ការផ្សាំក្នុងថង់..........0៤

៤-ការដាំដុះ..........0៥

ក. ការជ្រើសរើសទីកន្លែងដាំដុះ.......... 0៥

ខ. របៀបជីករណ្តៅ..........0៥

គ. ការដាក់ជីក្នុងរណ្តៅ.......... 0៦

ឃ. ការដាំកូនខ្នុរ..........0៧

៥-ការថែទាំ..........0៨

ក. ការដាក់ជី..........0៨

ខ. ការស្រោចទឹក..........0៩

គ. ការពាក់តែងមែក..........១0

ឃ. ការការពារជម្ងឺ និង សត្វល្អិតចង្រៃ.......... ១១

៦- ការប្រមូលផល..........១១

៧- ការបន្តពូជ..........១២

ក.ការបន្តពូជដោយគ្រាប់..........១២

ខ. ការបន្តដោយសាកមែក..........១២

## ១- សេចក្ដីផ្ដើម

ខ្នុរគឺជារុក្ខជាតិមួយដែលកសិករភាគច្រើននិយមចូលចិត្តដាំ ព្រោះអាចដុះលូតលាស់បានលើដីស្ទើរតែគ្រប់ប្រភេទ។ វាមានប្រយោជន៍ច្រើនយ៉ាងដូចជា សាច់ និង គ្រាប់ផ្លែទុំធ្វើជាបង្អែម ផ្លែខ្ចីធ្វើជាបន្លែ ដើមធ្វើជាគ្រឿងសង្ហារឹមផ្សេងៗ ជារបាំងខ្យល់ ជាម្លប់ និង ស្លឹកជាជី ។

## ២- ការជ្រើសរើសពូជ

ប្រភេទខ្នុរដែលអាចយកមកដាំបាននោះគឺ ពូជឆាប់ផ្លែ ធនជំងឺ និង សត្វចង្រៃ ផ្លែធំក្លែបមានសាច់ក្រាស់មានសាញតិច រស់ជាតិផ្អែម ក្លិនក្រអូប ផ្លែស្មើរជ្រុងល្អ មានប្រភពច្បាស់លាស់ សាច់រក្សាទុកបានយូរ និង តម្រូវសំរាប់ទីផ្សារខ្ពស់ ។



## ៣- ការបណ្ដុះកូន

### ក. ជ្រើសរើសទីតាំងថ្នាល:

ទីតាំង និង ការរៀបចំថ្នាលជាកត្តាមួយដ៏សំខាន់សំរាប់ធ្វើអោយការដុះពន្លក នៃកូនដំណាំបានគង់វង់ក្នុងបរិមាណខ្ពស់ និង មានសុខភាពល្អនោះដូចជា ៖- ជិតប្រភពទឹក ដីទួលមិនលិចទឹក មានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ និង ជាទីកន្លែងដែលមានសុវត្ថិភាព ។

### ខ. ការរៀបចំថ្នាល:

ត្រូវលើកដីថ្នាលអោយបានកំពស់ពីរតឹក ទទឹងមួយម៉ែត្រ និង បណ្ដោយ អាស្រយ័ទៅ តាមប្រវែងជាក់ស្ដែងដែលចង់បាន កាប់ដីអោយម៉ត់ ហាលរយៈពេលពីរ ទៅ បី សប្ដាហ៍ដើម្បីសំលាប់ពពួកបាក់តេរី ឬ សត្វល្អិតចង្រៃផ្សេងៗ និង ជ្រោយដីរួចជ្រើសយក ស្មៅចេញ ។



## គ. ការបណ្ដុះកូនខ្នុរ

ត្រូវកប់គ្រាប់ខ្នុរដែលបានជ្រើសរើសរួចក្រោយពេលហូបសាច់ពីពីរ ទៅ បីថ្ងៃដាក់ពង្រាយលើរងដែលបានរៀបចំជាស្រេចគឺចំងាយប្រហែលពីរតឹក ពីគ្រាប់មួយ ទៅគ្រាប់មួយ លុបដី ម៉ត់ពីលើគ្រាប់អោយបានជិតល្អ គ្របកំណាត់ចំបើងចិញ្ច្រាំខ្លីៗ ស្រោចទឹកអោយសើមជាប្រចាំ។



## ឃ. <u>ការផ្សាំក្នុងថង់:</u>

រយៈពេលប្រហែលមួយខែក្រោយបន្ទាប់ពីបណ្ដុះក្នុងថ្នាលមក យើងអាចគាស់យកកូនខ្នុរទៅផ្សាំក្នុងថង់បាន ប៉ុន្តែថង់ត្រូវច្រកដោយ ដីកំប៉ុស្តិ៍មួយភាគ អង្កាមមួយភាគ និងដីខ្សាច់មួយភាគមុនជាស្រេច ហើយស្រោចទឹកភ្លាមដើម្បីអោយឬសចាប់ជាប់ដីថ្មីក្នុងថង់។



## ៤- ការដាំដុះ

### ក. ការជ្រើសរើសទីកន្លែងដាំដុះ:

ត្រូវដាំខ្នុរនៅកន្លែងណាដែល មានសុវត្ថិភាព ដីខ្ពស់ដែលមិនលិចទឹក តែមានសំណើមល្មម និង ដីមានជីជាតិល្អ ឆ្ងាយពីដើមឈើធំៗដែលមានស្រាប់យ៉ាងហោចណាស់១០ម៉ែត្រ មានប្រភពទឹកនៅជិតងាយស្រួលក្នុងការស្រោចស្រពនៅពេលជួបប្រទះភាពរាំងស្ងួត ។

### ខ. របៀបជីករណ្តៅ:

រណ្តៅដាំដែលទំហំសមល្មមគឺ ជំរៅមួយម៉ែត្រ បណ្តោយមួយម៉ែត្រ និង ទទឹងមួយម៉ែត្រ( មួយម៉ែត្របួនជ្រុង) គំលាតពីរណ្តៅមួយទៅរណ្តៅមួយយ៉ាងហោចណាស់៨ម៉ែត្រ ហើយត្រូវធ្វើយ៉ាងណាកំណត់ជួរអោយបានប៉ះ និង ពន្លឺព្រះអាទិត្យស្មើរៗគ្នា ។



គ.ការដាក់ជីក្នុងរណ្តៅ:

ក្រោយពេលជីករណ្តៅរួច មុនពេលដាំត្រូវប្រមូលសំរាមដែលបានពីរុក្ខជាតិ ផេះលាមកសត្វ ឬ ដីកំប៉ុស្តិ៍ដាក់ក្នុងរណ្តៅអោយបានច្រើនជាការប្រសើរព្រោះវាជាជីធម្មជាតិដែលផ្ទុកទៅដោយអាហារធាតុចិញ្ចឹមច្រើនយ៉ាង ។



## ឃ. ការដាំកូនខ្នុរៈ

ត្រូវពិនិត្យ និង អនុវត្តិអោយបានហ្មត់ចត់ដូចជា កូនខ្នុរត្រូវមានអាយុយ៉ាងតិចពីរខែ ត្រូវច្បេវថង់ថ្នមៗដោយកាំបិតមុតការពារកុំអោយបែកដី ដាំនៅពេលល្ងាចដើម្បីអោយវាទទួលសំណើមពេលយប់ និង ស្រោចទឹកដើម្បីអោយឬសឆាប់ចាប់ជាប់និងដីថ្មី ។



## ៥- ការថែទាំ

### ក. ការដាក់ជិបំប៉ន:

ជីបំប៉ន់ត្រូវដាក់ពីរដងក្នុងមួយឆ្នាំនៅរៀងរាល់ដើម និង ចុងរដូវវស្សាជីករណ្ដៅព័ទ្ធជុំវិញគល់ខ្ទុរដោយគិតចំងាយពីគល់ទៅចុងមែកដែលបែកចេញទៅខាងវែងជាងគេជុំវិញដើម ជុំរៅកន្លះម៉ែត្រ ទំហំពីពីរ ទៅ បួនតឹក ដាក់ធម្មជាតិ និង ជីគីមីសមាសដែលមានធាតុ អ៊ិន ប៉េ កា។




ដាក់ជីបំប៉ននៅដើម និងចុងរដូវវស្សា ។

ខ. <u>ការស្រោចទឹក</u>ៈ

ការស្រោចទឹកគឺធ្វើឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់រោមជញ្ជក់របស់ឫស ងាយស្រួលស្រូបយកអាហារធាតុ ស្រោចទឹកបំប៉នអោយបានទៀងទាត់នៅពេលកូនខ្នុរនៅតូច ស្រោចទឹកពេលណាដែលយើងសង្កេតឃើញថាដំណាំខ្នុរខ្វះជាតិទឹក នៅពេលវាពេញវ័យស្រោចទឹកបំប៉នអោយបានច្រើនជាប្រចាំនៅមុន និង ក្នុងពេលដំណាំខ្នុរចេញផ្កា ។



គ. ការតាក់តែងមែកៈ

ការតាក់តែងមែកគឺត្រូវធ្វើឡើងរៀងរាល់បួនឆ្នាំម្តង ក្រោយពេលប្រមូលផលរួច ហើយមែកដែលត្រូវកាត់ចោលនោះមានដូចជាៈ- មែកចាស់មិនផ្តល់ផ្លែ មែកចុងសំយុងចុះ មែកដុះចាក់ទៅក្នុង មែកមានជំងឺ និង មែកមានដុះរុក្ខជាតិបញ្ញើរក្អែក ។ ការធ្វើរបៀបនេះដើម្បី អោយសុខភាពដើមល្អទទួយពន្លឺបានគ្រប់គ្រាន់ និង ស្រូបយក ខ្យល់បានល្អធ្វើអោយខ្នុរផ្លែធំ ។



ឃ. ការការពារជម្ងឺ និងសត្វចង្រៃ

យើងមានវិធីច្រើនយ៉ាងដូចជា ត្រូវដាក់កំបោរស សាចជូរខៀវ និង ស្ពាន់ធ័រ ជុំវិញគល់ ការពារសត្វកន្លៀវ ប្រើថ្នាំគីមីពុលកសិកម្មម៉ាឡាចុងនៅពេលសត្វល្អិតបំផ្លាញផ្កា ឬ ក្តិប(រាល់ពេលដែលប្រើថ្នាំពុលត្រូវដាក់ផ្លាកសញ្ញាសំគាល់ជៀសវាងមានគ្រោះថ្នាក់ដល់មនុស្ស) មែកដែលមាន ជំងឺត្រូវ កាប់រួចយកទៅកប់ ឬ ដុតចោល និង បំពក់ភ្លើង ដើម្បីអោយផ្សែងបណ្តេញសត្វល្អិត ។

## ៦-ការប្រមូលផល

ការប្រមូលផលដើម្បីរក្សាគុណផ្លែ និង មានតំលៃខ្ពស់នៅលើទីផ្សារគឺនៅពេលផ្លែទុំមានក្លិនក្រអូប(ស្រគាល)ងាយស្រួលក្នុងការលើកដាក់សំរាប់ដឹកយកទៅទីឆ្ងាយ និង លក់ដូរ មិនត្រូវទុកអោយទុំពេកទេ ព្រោះវាត្រូវមានការបំផ្លាញពីសំណាក់សត្វផ្សេងៗ និង ងាយរលួយ ។ ត្រូវកាត់ចន្លង់ដោយកាំមុត រួចច្រកចូលការុងដាក់ថ្មមៗ ជៀសវាងការជ្រុះមកប៉ះដីផ្ទាល់ ធ្វើអោយផ្លែគ្រាំ ឬ បែក ។



## ៧-ការបន្តពូជ

យើងមានវិធីច្រើនយ៉ាងសំរាប់ធ្វើការបន្តពូជខ្នុរ ប៉ុន្តែមានវិធីតែពីរទេដែលសមស្រប សំរាប់កសិករគឺមានដូចក្រោមៈ-

### ក. ការបន្តពូជដោយគ្រាប់:

ការបន្តពូជដោយគ្រាប់គឺជាវិធីមួយដែលមានលក្ខណៈល្អ និង ងាយស្រួលជាងគេ។ ការដាំដោយគ្រាប់គឺលូតលាស់បានល្អ មានប្រពន្ធ័ឫសមាំ ធនទ្រាំជម្ងឺ និង មានអាយុកាលលូតលាស់វែង ប៉ុន្តែមានការចុះតូចនៃទំហំផ្លែពីមួយជំនាន់ទៅមួយជំនាន់ ចំពោះពូជមួយចំនួន។

### ខ. ការបន្តដោយសាកមែក:

ការដាំខ្នុរដោយមែកសាកឆាប់អោយផលគឺក្នុងរយៈពេល ពីពីរ ទៅ បីឆ្នាំក្រោយពេលដាំតែប៉ុណ្ណោះ ប៉ុន្តែវាមានអាយុខ្លីជាងការដាំដោយគ្រាប់ព្រោះការលូតលាស់នៃឫស និង ដើមពុំមានតុល្យភាពគ្នា ។ ការសាកមែកត្រូវធ្វើតាមរបៀបដុចជា ជ្រើរើសមែកណាដែលមានសុខភាពល្អ ប្រវែងមិនលើសពីមួយម៉ែត្រ លាក់សំបកក្រឡឹងជុំវិញមែកដែលមានប្រវែងទៅតាមទំហំនៃមែក បកសំបកចេញ កោសរំអិល ទុកប្រហែពី១៥ ទៅ ៣០នាទី ចងថង់ផ្លាស់ស្ទិកដែលច្រកពេញដោយកំប៉ុស្តិ៍សើមជុំវិញមែកដែលកោសរួច ចងខ្សែរិតចំកណ្តាលអោយណែន ស្រោចទឹកអោយសើមជាប្រចាំ និង កាត់យកទៅច្រកក្នុងថង់ដើម្បីផ្សាំនៅពេលដែលយើង សង្កេតឃើញថាឫសដែលដុះមានពណ៌ត្នោត ។

ម.ព.ឯ.ក AIDOC
Code:
Date:
Donated by:

